San Diego City Schools

លិខិតពត៌មាន — រដូវស្លឹកឈើលាស់ឆ្នាំ ២០០២

# ការឆ្លើយតប ពេលមានភាពអាសន្ន

ចាប់ពីឆ្នាំ ១៩៩៩ ច្បាប់កាលីហ្វ័រញ៉ាបានតម្រូវថា ចាងហ្វាងប្រចាំសាលារៀននិមួយៗត្រូវតែសរសេរ ព្រមទាំងរក្សារគម្រោងការពារសន្តិសុខសាលារៀន។ ក្រសួងប៉ូលីសសាលារៀនបានផ្តល់ការហ្វឹកហ្វឺន យ៉ាងច្បាស់លាស់ដល់ចាងហ្វាងនូវទម្រង់ឆ្លើយតប ពេលមានភាពអាសន្ន។ វីឌីអូថេពត្រូវបានផលិតឡើង ព្រមទាំងចែកចាយដល់បុគ្គលិកហ្វឹកហ្វឺនថ្មីទាំងអស់នៅតាមសាលារៀន។

ឆ្នាំ ២០០០ ក្រសួងប៉ូលីសសាលារៀនបានប្រតិបត្តិ **ប្រអប់សំរាប់ឆ្លើយតបនឹងវិបត្តិទូទៅ (CRB)** នៅតាមសាលារៀនិមួយៗរបស់យើង និងមជ្ឈមណ្ឌលបណ្តុះបណ្តាលសិស្សទាំងអស់។ **CRB**និមួយៗផ្ទុកមាននូវគម្រោងណែនាំឲ្យមានសន្តិសុខសាលារៀន សំរាប់ពេលមានភាពអាសន្ន ព្រមទាំងរក្សារទុកដោយចាងហ្វាងប្រចាំសាលារៀននិមួយៗ។ពេលមានភាពអាសន្ន ចាងហ្វាងប្រចាំសាលារៀន ឬបុគ្គលិកទទួលការហ្វឹកហ្វឺននឹងបើកគម្រោងការណ៍នោះ ហើយអនុវត្តន៍តាមលំនាំនៅក្នុង **CRB** ។

គម្រោងការពារសន្តិសុខត្រូវបានសរសេរឡើងដោយចាងហ្វាងជាប្រចាំឆ្នាំ និងមានការត្រួតពិនិត្យមើលដោយការិយាល័យក្រសួងប៉ូលីស។ រៀងរាល់ឆ្នាំ សមាជិកក្រុមមានរួមដូចជា: ចាងហ្វាង, ចាងហ្វាងរង, លោកគ្រូ-អ្នកគ្រូ, សិស្ស និងមាតាបិតា ពីររូប (២) ពិនិត្យមើល និងកែតម្រូវគម្រោងការនេះ។ គម្រោងសន្តិសុខចម្លងមួយច្បាប់ទុកនៅ**CRB** ពេលមានភាពអាសន្នហើយមួយច្បាប់ទៀតទុកនៅលើតុការិយាល័យធំសំរាប់មាតាបិតានិង/ឬបុគ្គលិកសាលាធ្វើការសើរើ។មាតាបិតា/អ្នកអាណាព្យាបាលសិស្សម្នាក់ៗ អនុញ្ញាតិឲ្យសើរើគំរោងសន្តិសុខ និងអាចផ្តល់ជាយោបល់-មតិដល់ចាងហ្វាងពេលណាក៏បានដែរ។

**CRB** និមួយមានលំនាំសំរាប់ប្រើប្រាស់ពេលមានភាពអាសន្ន, បញ្ជីឈ្មោះសិស្សតាមកំរិតថ្នាក់, ផែនទីថ្មី, គម្រោងការពារមហន្តរាយ, ផ្លូវជម្លៀសចេញ, ការបង្កើតទីតាំង, រូបថតសាលា, គម្រោងការពារឧក្រិដ្ឋកម្ម, និងពត៌មានផ្សេងៗដែលតម្រូវដោយច្បាប់។ ចាងហ្វាងសាលារៀននិមួយៗត្រូវមានគម្រោងចម្លងចំនួន ពីរច្បាប់ (២) ដាក់នៅតាមសាលារៀនរបស់ខ្លួន។

យោងទៅតាមភាពអាសន្ន ចាងហ្វាងសាលារៀននិមួយៗត្រូវតែកំណត់ទីកន្លែងចំនួន ពីរកន្លែង សំរាប់សិស្សត្រូវជួបគ្នា បើចាំបាច់។ សិស្សទទួលការគ្រប់គ្រងដោយបុគ្គលិកសាលារៀនដែលទទួលការហ្វឹកហ្វឺន ហើយមិនអនុញ្ញាតិឲ្យចេញពីសាលារៀនដោយគ្មានការអនុញ្ញាតិឡើយ។ សាលារៀននឹងប្រើវិធីដោះស្រាយឲ្យសិស្ស និងមាតាបិតា/អ្នកអាណាព្យាបាលជួបគ្នា ឬអនុញ្ញាតិអោយចូលក្នុងសាលារៀន ក្រោយពេលមានសន្តិសុខ។បច្ចុប្បន្ននេះ បុគ្គលិកចាត់តាំងពិសេសរបស់ក្រសួងអប់រំប្រចាំក្រុងធ្វើការហ្វឹកហ្វឺនជាក្រុមដោះស្រាយការជួបជុំគ្នាដែលនឹងអញ្ជើញចូលទៅតាមសាលារៀន ដើម្បីជួយដោះស្រាយអំពី ការរៀបចំតាមកំរិតថ្នាក់និមួយៗ។ ចំណុចនេះ មាតាបិតាតម្រូវឲ្យចុះហត្ថលេខាលើទម្រង់លិខិតទទួលកូនរបស់ខ្លួនទៅផ្ទះ។ ពេលមានភាពអាសន្នកើតមានឡើង ក្រសួងពត៌មានសាធារណៈនឹងចុះផ្សាយផ្តល់ពត៌មានដល់មាតាបិតា និងសហគមន៍ឲ្យបានជ្រាបអំពីការជួបជុំគ្នា ហើយវិធីផ្សេងៗដែលមាតាបិតាត្រូវប្រតិបត្តិតាម ទាល់តែមាតាបិតាទទួលទូរស័ព្ទពីសាលារៀន។

> ## សង្ខេប
>
> - រឿងសំខាន់ទី ១ សំរាប់ប៉ូលីសសាលា និងបុគ្គលិកសាលាគឺជួយថែរក្សាសិស្ស និងបុគ្គលិកសាលារៀនទាំងអស់ឲ្យមានសន្តិសុខ
> - ពេលសាលាមានភាពអាសន្ន ជាទូទៅសិស្សមានសន្តិសុខនៅក្នុងសាលារៀន
> - មាតាបិតាត្រូវការរក្សាភាពស្ងាត់ស្ងៀម និងទប់ចិត្ត
> - មាតាបិតាត្រូវតែរក្សាលេខអត្តសញ្ញាណប័ត្រសិស្សជាប់ខ្លួនជានិច្ចរាល់ពេលវេលា
> - មាតាបិតាត្រូវតែប្រាប់ លេខទូរស័ព្ទថ្មី ដល់សាលារៀន សំរាប់ពេលមានភាពអាសន្ន
> - ក្រសួងសាធារណៈនឹងផ្សាយដំណឹងដល់មាតាបិតាឲ្យបានជ្រាបនូវជួបជាមួយកូននៅតាមសាលារៀន និងប្រតិបត្តិតាមការប្រាប់ លុះត្រាទាល់តែគេទូរស័ព្ទជម្រាបប្រាប់
> - ពេលមានភាពអាសន្ននៅតាមសហគមន៍ ក្រសួងពត៌មានសាធារណៈនឹងប្រើប្រព័ន្ធទូរស័ព្ទពិសេសសំរាប់មាតាបិតា និងសិស្សធ្វើការឆ្លើយតបនឹងសំនួររបស់ពួកគេ។

ចាងហ្វាង, ចាងហ្វាងរង, និងបុគ្គលិកចាត់តាំងបានទទួលការហ្វឹកហ្វឺនវគ្គប្រជុំសិក្សាអំពី ការប្រុងប្រយ័ត្នពេលមានភាពអាសន្ន, និងចាត់ចែងពេលមានគ្រោះថ្នាក់អ្វីមួយកើតមានឡើង, បុគ្គលិកហ្វឹកហ្វឺនប្រតិបត្តិគម្រោងសន្តិសុខ, ការស្រាវជ្រាវផ្អែកតម្រាមកំហែង, ការជួយគេចពីគ្រោះថ្នាក់ និងយុទ្ធវិធីណែនាំមាតាបិតាសិស្សជួបជុំគ្នា។នៅចុងឆ្នាំសិក្សា ២០០៣ ក្រសួងប៉ូលីសនឹងជ្រើសរើសសាលារៀនចំនួន ប្រាំបួន (៩) សាលា ដើម្បីធ្វើការសាកល្បង និងរៀបចំរបៀបគេចពីគ្រោះថ្នាក់ ពេលមានភាពអាសន្ន។ ក្រោយពីពេលសាកល្បងរួច គេនឹងស្នើសុំឲ្យផ្តល់ជាយោបល់-មតិដើម្បីធ្វើឲ្យបានល្អទៅថ្ងៃមុខ។

រដូវស្លឹកឈើធ្លាក់ឆ្នាំ ២០០២ មជ្ឈមណ្ឌលប្រតិបត្តិការ ពេលមានភាពអាសន្ន (**EOC**) បានចាប់ផ្តើមតាមច្បាប់មាតិការរដ្ឋ។ EOC ប្រតិបត្តិ ពេលសាលារៀន ឬក្រសួងអប់រំប្រចាំក្រុងអនុវត្តការរំដោះសិស្សឲ្យមានសន្តិសុខនៅតាមសាលារៀនណាមួយ។ គោលបំណងនៃគម្រោងនេះគឺសហការនិងផ្តល់ពត៌មានជូនដល់មាតាបិតា/អ្នកអាណាព្យាបាលសិស្សឲ្យបានជ្រាប រួមនឹងសហការយ៉ាងពេញទំហឹងដែលមានទំនាក់ទំនងជាមួយអង្គការក្នុងក្រុង, ស្រុក, និងសហព័ន្ធ។

- ពត៌មានបន្ថែមស្តីអំពី ការឆ្លើយតប ពេលមានភាពអាសន្ន មាននៅទំព័រម្ខាងទៀត -

បោះពុម្ពដែលមានការគាំទ្រពីសមាគម Annie E. Casey

ទាក់ទងពត៌មាន: ក្រសួងផ្នែក ចំរើ (៦១៩) ៧២៥-៨៦១០ www.sandi.net
ការតម្រូវតាមសាធារណៈ (៦១៩) ៧២៥-៨៤៧៨

ការបំរើសិស្សជាង ១៣៨០០០នាក់, សាលារៀនប្រចាំទីក្រុង សាន់ឌីអេហ្គោ គឺជាសាលារៀនប្រចាំក្រុងធំទី ពីរ ក្នុងចំណោមសាលារៀនទាំងអស់នៅក្នុងរដ្ឋ កាលីហ្វ័រញ៉ា ដែលមានមណ្ឌលចំនួនជាង ២០០ ព្រមទាំងបុគ្គលិកចំនួន ១៤៥០០នាក់ធ្វើការពេញម៉ោង (តំណាងបុគ្គលិកជាង ១៨៨០០នាក់)។ SDCS ពង្រឹងការអប់រំសិស្សតាមជំនាញគោលការអប់រំផ្អែក រៀនអាន, សរសេរ និងគណិតសាស្ត្រ។ ក្រសួងអប់រំប្រចាំក្រុងផ្តាច់ញ៉ាគាំទ្រសាលារៀន និងបង្កើនបរិយាកាសដល់សិស្សសិក្សានៅតាមបន្ទប់រៀនដោយកែប្រែមណ្ឌលសិក្សា និងទទួលប្រភពពត៌មានទូទៅ និងតាមមាតាបិតាសិស្ស, ការទាក់ទងពីលោកគ្រូ-អ្នកគ្រូ និងសហគមន៍តាមរបៀបអប់រំ។

" បេសកកម្មរបស់ក្រសួងអប់រំប្រចាំទីក្រុង សាន់ឌីអេហ្គោ គឺពង្រឹងការសិក្សាសិស្សឲ្យបានសម្រេច ដោយគាំទ្រការបង្រៀនរបស់លោកគ្រូ-អ្នកគ្រូ ព្រមទាំងការសិក្សារបស់សិស្សនៅតាមបន្ទប់រៀន។ "

បន្ថែមការព្យាយាមក្នុងចំណោមផ្នែកសុខាភិបាល, ផ្នែកផ្តល់ឱវាទ និងណែនាំ, ផ្នែកចាត់ចែង, មជ្ឈមណ្ឌលការសិក្សា, ទំនាក់ទំនងការប្រស្រ័យទាក់ទង និងសហគមន៍, និងក្រសួងផ្នែកសហការណ៏មាតាបិតា ផ្តល់ការកែប្រែ ព្រមទាំងពង្រឹងការប្រុងប្រៀបការពារ ពេលមានភាពអាសន្ន។

**ក្រសួងសុខាភិបាល** ផ្តល់ពត៌មានថ្មីៗ ព្រមទាំងប្រតិបត្តិ **គម្រោងការជួយអន្តរាគមន៍ផលវិបត្តិ។** ក្រសួងនេះផ្តល់ការឆ្លើយតបឲ្យបានយល់ និងប្រព័ន្ធឆ្លើយតប ពេលមានព្រឹត្តការណ៏កើតមានឡើងនៅតាមក្រសួងអប់រំប្រចាំក្រុង ឬសាលារៀន។ ការជួយធ្វើអន្តរាគមន៍ភ្លាមៗ និងការផ្តល់ពត៌មានគឺជាគន្លឹះការគាំទ្រផ្តល់ជំនួយដល់បុគ្គលទូទៅ ព្រមទាំងជួយដល់សាលារៀនឲ្យមានលក្ខណៈធម្មតាឡើងវិញ។

**DCRT - ក្រុមឆ្លើយតបដោះស្រាយទីងវិបត្តិរបស់ក្រសួងអប់រំប្រចាំក្រុង** សមាជិកទាំងអស់មានការហ្វឹកហ្វឺនខាងផ្នែកគំរូជួយចាត់ចែង ពេលមានបញ្ហាធ្ងន់ធ្ងរកើតមានឡើង (CISM) ដែលមានការហ្វឹកហ្វឺនជួយគាំទ្រ និងជួយឆ្លើយតបចម្លើយដល់សិស្ស, បុគ្គលិកសាលារៀន, និងសហគមន៍ដើម្បីជួយដោះស្រាយស្ថានការទាំងនោះ។ ពេលមានភាពអាសន្នកើតមានឡើង ក្រុមឆ្លើយតបដោះស្រាយទីងវិបត្តិរបស់ក្រសួងអប់រំប្រចាំក្រុងនឹងបញ្ចេញសកម្មភាពជួយដល់សាលារៀនដើម្បីដោះស្រាយផលវិបត្តិនិមួយៗ។

សាលា **CRT - ក្រុមឆ្លើយតបដោះស្រាយទីងវិបត្តិ** ធ្វើការបំរើទាក់ទងជាដំបូង និងផ្តល់ពត៌មានទូទៅ។ ចាងហ្វាងប្រចាំសាលារៀននិមួយៗ ឬបុគ្គលិកចាត់តាំងធ្វើការចាត់ចែងក្រុមឆ្លើយតបដោះស្រាយទីងវិបត្តិ (CRT)។ ចាងហ្វាងទាំងអស់ទទួលការបង្រៀនបង្កើតគម្រោងការជួយអន្តរាគមន៍នៅតាមសាលារៀន ដែលមានរបៀបដោះស្រាយតាមវិធីលំដាប់លំដោយ ពេលមានផលវិបត្តិកើតមាននៅតាមសាលារៀនរបស់គាត់។

**ក្រសួងផ្នែកផ្តល់ឱវាទ និងណែនាំ** ផ្តល់ពត៌មាន និងការគាំទ្រដល់មាតាបិតា ព្រមទាំងកូនរបស់គាត់។ គ្រូផ្តល់ឱវាទត្រូវចាត់តាំងអោយទៅបំរើការងារនៅតាមសាលារៀននិមួយៗ និងចូលរួមជាមួយសមាជិកក្រុមឆ្លើយតបដោះស្រាយទីងវិបត្តិនៅតាមសាលារៀន។

បើលោកអ្នកជឿជាក់ថា កូនរបស់លោកអ្នកត្រូវការឱវាទ និងណែនាំបន្ថែម ចូរទូរស័ព្ទទៅជួបគ្រូផ្តល់ឱវាទជាដំបូង។ ចូរធ្វើការណាត់ជួប ឬរៀបចំកាលវិភាគដើម្បីពិគ្រោះអំពី ការចាប់អារម្មណ៏របស់លោកអ្នក។ គ្រូផ្តល់ឱវាទនឹងផ្តល់ការណែនាំបញ្ជូនទៅអង្គការដែលអាចជួយបានតាមការគួរសមរម្យ។

ចូរចងចាំថា គោលការណ៏របស់យើងគឺរៀបចំចាត់ចែងជួយដោះស្រាយបញ្ហាភាពអាសន្ន។ ចូរធ្វើចិត្តឲ្យស្ងប់ស្ងាត់ ព្រមទាំងជឿទុកចិត្តដល់យើង។

**ពេលមានភាពអាសន្ន ចូរពិគ្រោះ និងពន្យល់ណែនាំដល់កូនថា:**

- សិស្សមានសន្តិសុខ ពេលមានភាពអាសន្ន
- យោងទៅតាមខ្នាតប្រុងប្រយ័ត្នឲ្យមានកំរិតខ្ពស់របស់ទីក្រុង សាន់ឌីអេហ្គោ យើងបង្កើនសន្តិសុខសិស្សឲ្យដល់កំរិតខ្ពស់
- បង្កើនកំរិតការពារសន្តិសុខសិស្សឲ្យដល់កំរិតខ្ពស់បំផុត
- រំលឹកដល់កូនថា ពេលវេលាអាចជួយបំបាត់ទុក្ខព្រួយដល់សិស្សបាន

**ចូរចងចាំដើម្បី:**

- គាំទ្រ ព្រមទាំងផ្តល់ពត៌មានឲ្យបានច្បាស់លាស់
- ប្រាប់ដល់កូនលោកអ្នកអោយធ្វើការបញ្ជាក់អំពី អារម្មណ៏របស់ខ្លួន
- ស្តាប់ ព្រមទាំងយល់ដឹងអំពី អារម្មណ៏របស់កូន

បោះពុម្ពដែលមានការគាំទ្រពីសមាគម Annie E. Casey

ការបំរើសិស្សជាង ១៣៨០០០នាក់, សាលារៀនប្រចាំទីក្រុង សាន់ឌីអេហ្គោ គឺជាសាលារៀនប្រចាំក្រុងធំទី ពីរ ក្នុងចំណោមសាលារៀនទាំងអស់នៅក្នុងរដ្ឋ កាលីហ្វ័រញ៉ា ដែលមានមណ្ឌលចំនួនជាង ២០០ ព្រមទាំងបុគ្គលិកចំនួន ១៨៥០០នាក់ធ្វើការពេញម៉ោង (តំណាងបុគ្គលិកជាង ១៨៨០០នាក់)។ SDCS ពង្រឹងការអប់រំសិស្សតាមជំនាញគោលការអប់រំផ្នែក រៀនអាន, សរសេរ និងគណិតសាស្ត្រ។ ក្រសួងអប់រំប្រចាំក្រុងផ្តាច់ញ៉ាគាំទ្រសាលារៀន និងបង្កើនបរិយាកាសដល់សិស្សសិក្សានៅតាមបន្ទប់រៀនដោយកែប្រែមណ្ឌលសិក្សា និងទទួលប្រភពពត៌មានទូទៅ និងតាមមាតាបិតាសិស្ស, ការទាក់ទងពីលោកគ្រូ-អ្នកគ្រូ និងសហគមន៍តាមរបៀបអប់រំ។

" បេសកកម្មរបស់ក្រសួងអប់រំប្រចាំទីក្រុង សាន់ឌីអេហ្គោ គឺពង្រឹងការសិក្សាសិស្សឲ្យបានសម្រេច ដោយគាំទ្រការបង្រៀនរបស់លោកគ្រូ-អ្នកគ្រូ ព្រមទាំងការសិក្សារបស់សិស្សនៅតាមបន្ទប់រៀន។ "